# សេចក្តីថ្លែងការណ៍រួមនៃ
# កិច្ចប្រជុំកំពូលកម្ពុជា-ឡាវ-វៀតណាម លើកទី៩
# ស្តីពីតំបន់ត្រីកោណអភិវឌ្ឍន៍

**យើង** ជាប្រមុខរដ្ឋាភិបាលនៃ ព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ និង សាធារណរដ្ឋសង្គមនិយមវៀតណាម (តទៅនេះហៅកាត់ថា CLV) បានជួបប្រជុំគ្នា ដើម្បីចូលរួមកិច្ចប្រជុំកំពូល CLV លើកទី៩ នៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ នៅទីក្រុងសៀមរាប នៃព្រះរាជាណាចក្រកម្ពុជា ។

**រំលឹកឡើងវិញ** នូវការប្តេជ្ញាចិត្តរបស់យើង ចំពោះការអភិវឌ្ឍតំបន់ត្រីកោណអភិវឌ្ឍន៍កម្ពុជា-ឡាវ-វៀតណាម ប្រកបដោយចីរភាពនិងបរិយាប័ន្ន កាត់បន្ថយភាពក្រីក្រ និងវិសមភាពសេដ្ឋកិច្ចនិងសង្គម និងធ្វើឱ្យប្រសើរឡើង នូវជីវភាពរស់នៅរបស់ប្រជាជន ក្នុងតំបន់ត្រីកោណអភិវឌ្ឍន៍។

**បញ្ជាក់ឡើងវិញ** នូវការប្តេជ្ញាចិត្តរបស់យើងក្នុងការពង្រឹង និងធ្វើឱ្យកាន់តែស៊ីជម្រៅបន្ថែមទៀត ចំពោះកិច្ចសហប្រតិបត្តិការ និងការអភិវឌ្ឍគ្រប់ជ្រុងជ្រោយក្នុងចំណោមប្រទេសកម្ពុជា-ឡាវ-វៀតណាម ដោយផ្អែកលើទំនាក់ទំនងជាប្រពៃណី មិត្តភាព សាមគ្គីភាព និងកិច្ចសហប្រតិបត្តិការដែលផ្តល់ផលប្រយោជន៍ទៅវិញទៅមក និងភាពជាអ្នកជិតខាងល្អ។

**បញ្ជាក់ឡើងវិញ** នូវការប្តេជ្ញាចិត្តរបស់យើង ក្នុងការបំពេញការងារជិតស្និទ្ធជាមួយប្រទេសសមាជិកអាស៊ានដទៃទៀត ដើម្បីសម្រេចបានចក្ខុវិស័យសហគមន៍អាស៊ានឆ្នាំ២០២៥។

**កត់សម្គាល់** នូវវឌ្ឍនភាព និងបញ្ហាប្រឈម ក្នុងការអនុវត្តផែនការមេកែសម្រួលសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម នៃតំបន់ CLV DTA សំរាប់ឆ្នាំ២០១០-២០២០ ចាប់ពីកិច្ចប្រជុំកំពូល CLV លើកទី៨ នៅទីក្រុងវៀងចន្ទន៍ ឆ្នាំ២០១៤។

**ទទួលស្គាល់** អំពីតម្រូវការក្នុងការប្រើប្រាស់ឱ្យបានប្រសើរជាងមុននូវសក្តានុពលអភិវឌ្ឍន៍ និងធនធានដែលមានរបស់ប្រទេសកម្ពុជា-ឡាវ-វៀតណាម និងការកៀរគរជំនួយបច្ចេកទេស និងហិរញ្ញវត្ថុ ពីដៃគូអភិវឌ្ឍន៍ និងស្ថាប័នអន្តរជាតិនានា។

**យើងប្រកាសថា៖**

១. យើងបញ្ជាក់ឡើងវិញនូវការប្តេជ្ញាចិត្តធ្វើការជាមួយគ្នាជិតស្និទ្ធ ដើម្បីលើកកម្ពស់ទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការនៃតំបន់ CLV DTA ដោយផ្អែកលើមិត្តភាពជាប្រពៃណី ការយោគយល់គ្នាទៅវិញទៅមក ការជឿទុកចិត្តគ្នា និងកិច្ចសហប្រតិបត្តិការគ្រប់ជ្រុងជ្រោយ។

២. យើងផ្តល់តម្លៃខ្ពស់ចំពោះកិច្ចការ និងកិច្ចខិតខំប្រឹងប្រែងរបស់គណៈកម្មាធិការសម្របសម្រួលចម្រុះ CLV ក្នុងការអនុវត្តផែនការមេកែសម្រួលសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមនៃតំបន់ CLV DTA សម្រាប់ឆ្នាំ ២០១០-២០២០ និងវាយតម្លៃខ្ពស់ចំពោះលទ្ធផលនៃកិច្ចប្រជុំលើកទី១០ របស់គណៈកម្មាធិការសម្របសម្រួលចម្រុះតំបន់ត្រីកោណអភិវឌ្ឍន៍កម្ពុជា-ឡាវ-វៀតណាម (JCC) និងកិច្ចប្រជុំពាក់ព័ន្ធ ដែលបានប្រព្រឹត្តទៅពីថ្ងៃទី៧-១១ ខែធ្នូ ឆ្នាំ២០១៥ នៅទីក្រុងប៉ាកសេ ខេត្តចំប៉ាសាក់ នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ។

៣. យើងវាយតម្លៃខ្ពស់ចំពោះការចូលរួមយ៉ាងសកម្មពីក្រសួង-ស្ថាប័ន និងអាជ្ញាធរខេត្តរបស់ប្រទេសកម្ពុជា-ឡាវ-វៀតណាម នៅក្នុងគ្រប់ព្រឹត្តិការណ៍ទាំងអស់របស់តំបន់ CLV DTA ដែលបានប្រារព្ធធ្វើចាប់ពីថ្ងៃទី៧-១១ ខែធ្នូ ឆ្នាំ២០១៥ នៅទីក្រុងប៉ាកសេ ខេត្តចំប៉ាសាក់។ យើងលើកទឹកចិត្តឱ្យប្រទេសកម្ពុជា-ឡាវ-វៀតណាម ឱ្យបន្តនិងបង្កើនសកម្មភាពទាំងនោះ ដើម្បីលើកស្ទួយកិច្ចសហប្រតិបត្តិការក្នុងចំណោមប្រជាជន និងសហគមន៍ធុរកិច្ច ក្នុងតំបន់ CLV DTA។

៤. យើងកោតសរសើរចំពោះលទ្ធផលនៃវេទិកាយុវជន និងការតាំងពិព័រណ៍ពាណិជ្ជកម្ម និងទេសចរណ៍ និងសន្និសីទស្តីពីការជំរុញពាណិជ្ជកម្ម វិនិយោគ និងទេសចរណ៍ ក្នុងតំបន់ CLV DTA ដែលបានប្រារព្ធធ្វើនៅថ្ងៃទី៧-១១ ខែធ្នូ ឆ្នាំ២០១៥ នៅប៉ាកសេ ខេត្តចំប៉ាសាក់ សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ។ យើងលើកទឹកចិត្តដល់យុវជន សហគមន៍ធុរកិច្ច និងវិស័យឯកជន ឱ្យបន្តចូលរួមយ៉ាងសកម្មក្នុងវេទិកាយុវជន និងពិព័រណ៍ពាណិជ្ជកម្ម និងទេសចរណ៍ ព្រមទាំងព្រឹត្តិការណ៍ជំរុញពាណិជ្ជកម្ម វិនិយោគ និងទេសចរណ៍ ក្នុងចំណោមប្រទេសកម្ពុជា-ឡាវ-វៀតណាម ដើម្បីជំរុញការផ្លាស់ប្តូរនិងទំនាក់ទំនងទៅវិញទៅមករវាងយុវជន និងបង្កើនលំហូរពាណិជ្ជកម្ម វិនិយោគ និងទេសចរណ៍ ចូលមកក្នុងតំបន់ CLV DTA។

៥. យើងស្វាគមន៍លទ្ធផលនៃកិច្ចប្រជុំគណៈកម្មការ/គណៈកម្មាធិការលើកទី២ និងទី៣ ស្តីពីកិច្ចការពារជាតិ និងសន្តិសុខ របស់សភាជាតិនៃប្រទេសកម្ពុជា-ឡាវ-វៀតណាម នៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៥ នៅទីក្រុងប៉ាកសេ ខេត្តចំប៉ាសាក់ សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ និងនៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៦ នៅទីក្រុងញ៉ាត្រាង ខេត្តខាញ់ហ័រ ប្រទេសវៀតណាម។

៦. យើងបញ្ជាក់ឡើងវិញ អំពីសារៈសំខាន់នៃការធានាសន្តិសុខ សុវត្ថិភាព និងបរិយាកាសប្រកបដោយស្ថិរភាព សម្រាប់វិនិយោគិន ភ្ញៀវទេសចរណ៍ និងប្រជាជនរស់នៅក្នុងតំបន់ CLV DTA។ យើងនឹងពង្រឹងកិច្ចសហប្រតិបត្តិការ ដើម្បីប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរគ្រឿងញៀននិងមនុស្ស ឧក្រិដ្ឋកម្មឆ្លងព្រំដែន ភេរវកម្ម និងការបោសសម្អាតមីន និងយុទ្ធភណ្ឌមិនទាន់ផ្ទុះ និងកាកសំណល់ជាតិផ្ទុះបន្សល់ពីសង្គ្រាម។ យើងប្រគល់ភារកិច្ចនេះជូនអាជ្ញាធរពាក់ព័ន្ធឱ្យធ្វើការជិតស្និទ្ធក្នុងការរៀបចំកម្មវិធីកសាង និងផ្លាស់ប្តូរសមត្ថភាពនានា ដើម្បីដោះស្រាយបញ្ហាដូចបានលើកឡើងខាងលើ។

៧. យើងស្វាគមន៍ប្រទេសជប៉ុន និងដៃគូអភិវឌ្ឍន៍នានា ចំពោះការបន្តជួយដល់ការអភិវឌ្ឍតំបន់សម្រាប់ប្រទេសតាមបណ្តោយទន្លេមេគង្គ រួមទាំងតំបន់ CLV DTA ក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខ ទាក់ទងនឹងការបោសសម្អាតមីន និងការកំទេចចោលយុទ្ធភណ្ឌមិនទាន់ផ្ទុះ ជំនួយពិការភាព និងការថែទាំវេជ្ជសាស្ត្រក្នុងពេលមានគ្រោះមហន្តរាយ និងសង្គ្រោះបន្ទាន់។

៨. យើងបញ្ជាក់ឡើងវិញ អំពីការប្តេជ្ញាចិត្តអនុវត្តកិច្ចព្រមព្រៀងទ្វេភាគី និងពហុភាគី តាមដែលអាចអនុវត្តបានស្តីពីការធ្វើដំណើររបស់ប្រជាជន និងបម្លាស់ទីទំនិញនៅក្នុងតំបន់ CLV DTA ជាពិសេសកិច្ចព្រមព្រៀងស្តីពីការដឹកជញ្ជូនឆ្លងកាត់ព្រំដែន (CBTA) នៅក្រោមកម្មវិធីមហាអនុតំបន់ទន្លេមេគង្គ (GMS)។

៩. ការបង្កើតសហគមន៍សេដ្ឋកិច្ចអាស៊ានឆ្នាំ២០១៥ បានធ្វើឱ្យប្រសើរឡើងបន្ថែមទៀតនូវលំហូរដោយសេរីនៃទំនិញ សេវាកម្ម វិនិយោគ និងលំហូរមូលធននៅក្នុងតំបន់។ ក្នុងន័យនេះ យើងស្វាគមន៍ការបញ្ចប់ការចរចា និងការចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីពីការជំរុញ និងសម្រួលពាណិជ្ជកម្មសម្រាប់តំបន់ត្រីកោណអភិវឌ្ឍន៍កម្ពុជា-ឡាវ-វៀតណាម។ យើងប្តេជ្ញាចិត្តអនុវត្តកិច្ចព្រមព្រៀងនេះឱ្យបានជាផ្លែផ្កា ក្នុងគោលបំណងសម្រួលសកម្មភាពពាណិជ្ជកម្ម និងវិនិយោគ នៅក្នុងតំបន់ CLV DTA ដែលជាមធ្យោបាយកាត់បន្ថយគម្លាតអភិវឌ្ឍន៍រវាងតំបន់ CLV DTA ជាមួយនឹងតំបន់ដទៃទៀត។

១០. យើងស្វាគមន៍ពិធីសម្ពោធត្រីភាគីស្តីពីប្រតិបត្តិការដឹកជញ្ជូនឆ្លងព្រំដែន ដែលបានប្រារព្ធធ្វើនៅច្រកហ័រលើ ខេត្តបិញហ្វឿក ប្រទេសវៀតណាម និងច្រកត្រពាំងស្រែ ស្រុកស្នួល ខេត្តក្រចេះ ប្រទេសកម្ពុជា នៅថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០១៥ ស្របតាមការអនុវត្តអនុស្សរណៈនៃការយោគយល់គ្នាក្នុងចំណោមកម្ពុជា-ឡាវ-វៀតណាម ស្តីពីការដឹកជញ្ជូនតាមផ្លូវគោក។

១១. យើងស្វាគមន៍លទ្ធផលនៃកិច្ចប្រជុំឧត្តមមន្ត្រីលើកទី១១ និងកិច្ចប្រជុំពាក់ព័ន្ធស្តីពីតំបន់ CLV DTA ដែលបានប្រារព្ធធ្វើនៅខេត្តដាក់ណុង ប្រទេសវៀតណាម នាថ្ងៃទី៣១ ខែតុលា និងថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៦។

១២. យើងវាយតម្លៃខ្ពស់ចំពោះលទ្ធផលនៃរបាយការណ៍សិក្សា ស្តីពីការរៀបចំផែនការអភិវឌ្ឍន៍ឧស្សាហកម្មកៅស៊ូ ហើយប្រគល់ភារកិច្ចនេះជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនៃប្រទេសកម្ពុជា ក្រសួងកសិកម្ម និងរុក្ខាប្រមាញ់នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ និងក្រសួងកសិកម្មនិងអភិវឌ្ឍន៍ជនបទនៃប្រទេសវៀតណាម ដើម្បីរៀបចំសេចក្តីព្រាងផែនការអភិវឌ្ឍន៍ឧស្សាហកម្មកៅស៊ូ ដែលនឹងត្រូវដាក់ជូនកិច្ចប្រជុំកំពូល CLV លើកទី១០។ យើងលើកទឹកចិត្តក្រសួង-ស្ថាប័នពាក់ព័ន្ធ ស្វែងរកការគាំទ្រពីដៃគូអភិវឌ្ឍន៍នៅក្នុងការបង្កើតផែនការនេះ។

១៣. យើងបញ្ជាក់ឡើងវិញ អំពីការប្តេជ្ញាចិត្តយ៉ាងម៉ឺងម៉ាត់ចំពោះកិច្ចការពារបរិស្ថាន និងការប្រើប្រាស់និងគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពនូវធនធានធម្មជាតិ ដែលរួមមានធនធានទឹក និងព្រៃឈើ សម្រាប់ការអភិវឌ្ឍ

ប្រកបដោយចីរភាពក្នុងប្រទេសនីមួយៗ និងសម្រាប់តំបន់ CLV DTA ទាំងមូល។ ក្នុងន័យនេះ យើងលើកទឹកចិត្តឱ្យស្ថាប័នក្នុងតំបន់ និងស្ថាប័នពាក់ព័ន្ធ បន្តដាក់បញ្ចូលបញ្ហាផ្សេងៗដែលពាក់ព័ន្ធនឹងបរិស្ថាន និងការអភិវឌ្ឍដោយចីរភាព ទៅក្នុងរបៀបវារៈនៃប្រទេសទាំងបី និងបង្កើតកម្មវិធីរួមក្នុងវិស័យដូចជា វារីវប្បកម្មនិយម ការសម្របតាម និងការកាត់បន្ថយផលប៉ះពាល់នៃបម្រែបម្រួលអាកាសធាតុ ការគ្រប់គ្រងធនធានទឹក និងភូគព្ភសាស្ត្រ។

១៤. យើងទទួលស្គាល់នូវតម្រូវការបន្ទាន់ សម្រាប់ការចូលរួមបន្ថែមទៀតពីសហគមន៍ធុរកិច្ច និងវិស័យឯកជនសម្រាប់ការអភិវឌ្ឍតំបន់ CLV DTA។ យើងប្រគល់ភារកិច្ចនេះជូនគណៈកម្មាធិការសម្របសម្រួលចម្រុះដើម្បីអនុវត្តបន្ថែមទៀតនូវអនុស្សរណៈនៃការយោគយល់គ្នាដែលបានកែសម្រួល សំដៅការបង្កើតគោលនយោបាយអនុគ្រោះពិសេសសម្រាប់តំបន់ CLV DTA ដើម្បីបង្កើតបរិយាកាសអំណោយផលថែមទៀតដល់ធុរកិច្ច និងការវិនិយោគក្នុងតំបន់ CLV DTA។

១៥. យើងផ្តោតសំខាន់លើ សក្តានុពលនៃការអភិវឌ្ឍវិស័យទេសចរណ៍នៅក្នុងតំបន់ DTA ជាពិសេស ទេសចរណ៍សហគមន៍ អេកូទេសចរណ៍ និងទេសចរណ៍វប្បធម៌។ យើងលើកទឹកចិត្តឱ្យមានការសម្រួលដល់ការធ្វើដំណើរ និងទេសចរណ៍ ព្រមទាំងជំរុញប្រទេសបី-គោលដៅមួយ។ យើងប្រគល់ភារកិច្ចនេះ ជូនគណៈកម្មាធិការសម្របសម្រួលចម្រុះ ដើម្បីបង្កើតក្រុមការងារដែលមានតំណាងមកពីប្រទេសកម្ពុជា-ឡាវ-វៀតណាម ដើម្បីរៀបចំសេចក្តីព្រាង និងបញ្ចប់ផែនការអភិវឌ្ឍន៍ទេសចរណ៍តំបន់ CLV DTA ហើយដាក់ជូនកិច្ចប្រជុំកំពូល CLV លើកទី១០ ដើម្បីធ្វើការពិចារណា និងអនុម័ត។

១៦. យើងវាយតម្លៃខ្ពស់កិច្ចខិតខំប្រឹងប្រែងរបស់ក្រុមការងារជំនាញនៃប្រទេសទាំងបី ក្នុងការបង្កើតផែនការសកម្មភាពសម្រាប់ការតភ្ជាប់សេដ្ឋកិច្ចកម្ពុជា-ឡាវ-វៀតណាម រហូតដល់ឆ្នាំ២០៣០។ យើងប្រគល់ភារកិច្ចនេះជូនគណៈកម្មាធិការសម្របសម្រួលចម្រុះ និងក្រសួង-ស្ថាប័នពាក់ព័ន្ធ ឱ្យខិតខំបញ្ចប់ផែនការសកម្មភាពស្តីពីការតភ្ជាប់នេះ ហើយដាក់ជូនទៅកិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលចម្រុះលើកទី១១ ដើម្បីធ្វើការពិចារណា និងអនុម័ត។

១៧. យើងទទួលស្គាល់សារៈសំខាន់នៃការធ្វើបច្ចុប្បន្នភាពព័ត៌មានជាប្រចាំទៅលើគេហទំព័រ CLV ដោយប្រទេសទាំងបី។ យើងប្រគល់ភារកិច្ចនេះជូនគណៈកម្មាធិការសម្របសម្រួលចម្រុះ និងក្រសួង-ស្ថាប័នពាក់ព័ន្ធ ដើម្បីធ្វើវិសិដ្ឋកម្មបច្ចេកវិទ្យាសម្រាប់គេហទំព័រនេះ។

១៨. យើងសូមសម្តែងនូវអំណរគុណចំពោះដៃគូអភិវឌ្ឍន៍ និងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិនានា ដែលបានបន្តរួមចំណែកដល់ការអភិវឌ្ឍតំបន់ CLV DTA។ ក្នុងន័យនេះ យើងសូមអំពាវនាវរកជំនួយហិរញ្ញវត្ថុ និងបច្ចេកទេសបន្ថែមទៀតពីដៃគូអភិវឌ្ឍន៍ និងស្ថាប័នអន្តរជាតិសម្រាប់ការអភិវឌ្ឍតំបន់ CLV DTA។ យើងក៏យល់ព្រម

ពង្រឹងកិច្ចសហការរវាងតំបន់ CLV DTA និងក្របខណ្ឌសហប្រតិបត្តិការដទៃទៀតនៅក្នុងអនុតំបន់ទន្លេមេគង្គ ជាពិសេសកិច្ចសហប្រតិបត្តិការមេគង្គ-ជប៉ុន។

១៩. យើងសូមវាយតម្លៃខ្ពស់ ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ប្រទេសកម្ពុជា-ឡាវ-វៀតណាម ក្នុងការរៀបចំ និងបញ្ចប់គម្រោងអាទិភាពទាំង១៥ ដែលបានដាក់ជូនកិច្ចប្រជុំកំពូលកម្ពុជា-ឡាវ-វៀតណាម លើកទី៩ ហើយយើងសូមឯកភាពលើគម្រោងអាទិភាពទាំងនេះ សម្រាប់ការអនុវត្តនាពេលអនាគត។

២០. យើងឯកភាពរៀបចំកិច្ចប្រជុំកំពូលកម្ពុជា-ឡាវ-វៀតណាម លើកទី១០ នៅប្រទេសវៀតណាម ក្នុងឆ្នាំ២០១៨។

ធ្វើនៅទីក្រុងសៀមរាប ព្រះរាជាណាចក្រកម្ពុជា ជាបីច្បាប់ ជាភាសាអង់គ្លេស នៅថ្ងៃទីម្ភៃបី ខែវិច្ឆិកា ឆ្នាំពីរពាន់ដប់ប្រាំមួយ។

| | | |
|---|---|---|
| **រដ្ឋាភិបាលនៃ<br>ព្រះរាជាណាចក្រកម្ពុជា** | **រដ្ឋាភិបាលនៃ<br>សាធារណរដ្ឋប្រជាធិបតេយ្យ<br>ប្រជាមានិតឡាវ** | **រដ្ឋាភិបាលនៃ<br>សាធារណរដ្ឋសង្គមនិយម<br>វៀតណាម** |
| **សម្តេចអគ្គមហាសេនាបតី<br>តេជោ ហ៊ុន សែន<br>នាយករដ្ឋមន្ត្រី** | Thongloun Sisoulith<br>**នាយករដ្ឋមន្ត្រី** | Nguyen Xuan Phuc<br>**នាយករដ្ឋមន្ត្រី** |

# JOINT DECLARATION
# OF THE 9th CAMBODIA- LAOS- VIET NAM SUMMIT
# ON DEVELOPMENT TRIANGLE AREA

**WE,** the Heads of the Governments of the Kingdom of Cambodia, the Lao People's Democratic Republic and the Socialist Republic of Viet Nam (hereinafter referred to as CLV) gather for the Ninth CLV Summit on 23rd November 2016, in Siem Reap City, Kingdom of Cambodia;

**REITERATING** our commitments to the sustainable and inclusive development of CLV Development Triangle Area (DTA), reducing poverty and economic and social disparities, and improving the quality of life for people living in DTA;

**REAFFIRMING** our commitments to further strengthening and deepening comprehensive cooperation and development among CLV countries building upon our traditional relations of friendship, solidarity, mutually-beneficial cooperation, and good neighbourliness;

**REAFFIRMING** our commitments to working closely with other ASEAN Member States for the realization of ASEAN Community Vision 2025;

**NOTING** the progress and challenges in implementing the Revised Master Plan for socio-economic development of the CLV DTA for 2010-2020 since the 8th CLV Summit in Vientiane in 2014;

**RECOGNIZING** the need to make better use of development potentials and available resources of CLV countries, and to mobilize technical and financial assistance from development partners and international institutions;

***WE HEREBY DECLARE THAT:***

1. We reaffirm our commitments to working closely to promote the relationship and cooperation of the CLV DTA on the basis of our traditional friendship, mutual understanding, trust and comprehensive cooperation.

2. We highly value the work and efforts of the CLV Joint Coordination Committee to implement the Revised Master Plan for Socio-Economic Development of the CLV DTA for 2010-2020 and highly appreciate the outcomes of the 10th Meeting of the CLV DTA Joint Coordination Committee (JCC) and relevant meetings held on 7-11 December 2015 in Pakse, Champasak Province, Lao PDR.

3. We appreciate the active participation of the CLV countries' ministries/agencies and provincial authorities in all CLV DTA events that took place from 7-11 December 2015 in Pakse, Champasak Province. We encourage the CLV countries to continue and increase those activities in order to foster cooperation among people and business communities in the CLV DTA.

4. We commend the outcomes of the Youth Forum, the Trade and Tourism Fair and the Conference on Trade, Investment and Tourism Promotion in the CLV DTA held on 7-11 December 2015 in Pakse, Champasak Province, Lao PDR. We encourage the youth, business community and private sector to continue actively participating in the Youth Forum and the Trade and Tourism Fairs as well as trade, investment and tourism promotion events among the CLV countries in order to promote youth exchange and interaction and enhance trade, investment and tourism flows into the CLV DTA.

5. We welcome the outcomes of the Second and Third Meetings of Committees/Commission on National Defence and Security of the National Assembly of the CLV Countries on 28th September 2015 in Pakse, Champasak Province, Lao PDR and on 21st September 2016 in Nha Trang City, Khanh Hoa Province, Viet Nam, respectively.

6. We reaffirm the importance of ensuring security, safety and stable environment for investors, tourists and residents in the CLV DTA. We will strengthen our cooperation to fight against drugs and human trafficking, cross-border crimes, terrorism and to conduct clearance of landmines, unexploded ordnance and explosive remnants of war. We task relevant authorities to work closely in organizing capacity building and exchange programmes in dealing with the above-mentioned issues.

7. We welcome Japan and other development partners for their continued assistance to regional development for the Mekong countries including the CLV DTA in the coming years in the areas of removal of landmines and disposal of unexploded ordnance (UXO), disabilities aid, and disaster and emergency medical care.

8. We reaffirm our commitments to implement, where applicable, the bilateral and multilateral agreements on movement of goods and people in the CLV DTA, particularly the Cross Border Transport Agreement (CBTA) under the Greater Mekong Sub-region (GMS).

9. The establishment of the ASEAN Economic Community 2015 has further enhanced the free flow of goods, services, investment and freer flow of capital in the region. In this connection, we welcome the conclusion of the negotiations and the signing of the Agreement on Trade Promotion and Facilitation for Cambodia-Laos-Viet Nam Development Triangle Area. We are committed to fruitfully implement this Agreement with the aim to facilitate trade and investment activities in the CLV DTA as the way to bridge the development gaps between the CLV DTA and other regions.

10. We welcome the Tripartite Opening Ceremony on Cross-Border Transport Operation, held in Hoa Lu, Binh Phuoc Province, Viet Nam and Trapeang Sre, Kratie Province, Cambodia on 9th September 2015 in line with the implementation of the Memorandum of Understanding (MOU) between and among the Governments of Cambodia- Laos-Viet Nam on Road Transport.

11. We welcome the results of the 11th SOM and related Meetings on CLV DTA held in Dak Nong Province, Viet Nam on 31st October and 1st November 2016.

12. We highly appreciate the outcome of the Study Report on developing Rubber Industry Development Plan and task the Ministry of Agriculture, Forestry and Fisheries of Cambodia, Ministry of Agriculture and Forestry of Lao PDR and Ministry of Agriculture and Rural Development of Viet Nam, to draft the Rubber Industry Development Plan to be submitted to the 10th CLV Summit. We encourage relevant ministries and agencies to seek the support from development partners in developing the Plan.

13. We reaffirm our strong commitment to environmental protection and to the effective use and management of natural resources, including water resources and forest, for sustainable development in each country and the entire CLV DTA. In this regard, we encourage localities and relevant agencies to continue incorporating issues related to the environment and sustainable development into the cooperation agenda of the three countries; and develop joint programmes in areas such as hydrometeorology, climate change adaptation and mitigation, water management and geology.

14. We recognize the urgent need for more engagement of the business community and private sector for the development of the CLV DTA. We task the JCC to further implement the revised MOU towards the Formulation of Special Preferential Policies for the CLV DTA in order to create a more favourable environment for business and investment in the CLV DTA.

15. We emphasize the potential of tourism development in the DTA, especially community-based tourism, eco-tourism and cultural tourism. We encourage the facilitation of travel and tourism as well as promoting three countries one destination. We task the JCC to establish the task force comprising of CLV representatives to draft and finalize the CLV DTA Tourism Development Plan and submit it to the 10th CLV Summit for consideration and approval.

16. We highly appreciate the efforts of the three countries' task forces in developing an Action Plan for CLV Economic Connectivity up to 2030. We task the JCC and relevant ministries/agencies to make efforts to finalize the Action Plan on connectivity and to submit it to the 11th JCC for consideration and approval.

17. We acknowledge the importance of regularly updating information on the CLV website by the three countries. We task the JCC and relevant ministries/agencies to upgrade technology for the website.

18. We would like to express our appreciation to the development partners and international financial institutions for their continued contributions to the development of the CLV DTA. In this regard, we call for more financial and technical assistance from development partners and international institutions for the development of the CLV DTA. We also agree to strengthen the collaboration between the CLV DTA and other cooperation frameworks in the Mekong Sub-region, in particular the Mekong – Japan Cooperation.

19. We highly appreciate the effort of the CLV Countries in preparing and finalizing the 15 Priority Projects that have been submitted to this 9th CLV Summit and we duly endorse these priority projects for future implementation.

20. We agree to hold the 10th CLV Summit in Viet Nam in 2018.

**DONE** in Siem Reap City, Kingdom of Cambodia in three copies in English language, on the Day of Twenty-Three in the Month of November in the Year of Two Thousand and Sixteen.

| For the Government of the Kingdom of Cambodia | For the Government of the Lao People's Democratic Republic | For the Government of the Socialist Republic of Viet Nam |
|---|---|---|
| Samdech Akka Moha Sena Padei Techo Hun Sen<br>Prime Minister | Thongloun Sisoulith<br>Prime Minister | Nguyen Xuan Phuc<br>Prime Minister |